ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការជាតិភាសាខ្មែរ
លេខៈ ០២/០៩.គ.ជ.ភ.ខ.ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការផ្ទេរភារកិច្ច ប្រគល់ភារកិច្ច និងបន្ថែមសមាជិក នៃគណៈកម្មការបច្ចេកទេសនានារបស់គណៈកម្មាធិការជាតិភាសាខ្មែរ

---

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន គណៈកម្មាធិការជាតិភាសាខ្មែរ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ ៧៩២ អនក្រ.តត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលសមាសភាពនៃគណៈកម្មាធិការជាតិភាសាខ្មែរ

- បានឃើញអនុក្រឹត្យលេខ ៧៩១ អនក្រ.តត ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងសមាជិកបន្ថែមនៃគណៈកម្មាធិការជាតិភាសាខ្មែរ
- បានឃើញសេចក្ដីសម្រេចលេខ១២១ សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្ដីពីការបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិភាសាខ្មែរ
- បានឃើញសេចក្ដីសម្រេចលេខ១២៣ សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្ដីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ
- តាមការងារចាំបាច់របស់គណៈកម្មាធិការជាតិភាសាខ្មែរ

## សម្រេច

**ប្រការ១:**

ត្រូវបានផ្ទេរភារកិច្ច ដូចខាងក្រោម ÷

១- លោកស្រីសាស្ត្រាចារ្យបណ្ឌិត **ឡាំ ឆេង** ពីសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទវប្បធម៌និងវិចិត្រសិល្បៈ ឯកទេសសេដ្ឋកិច្ច ប្ដូរទៅជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

២- ឯកឧត្តម **ស៊ីន ផុស** ពីសមាជិកគណៈកម្មការនៃការបង្កើតពាក្យនិងកម្ចីពាក្យ ប្ដូរទៅជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ភាសាវិទ្យានិងអក្សរសិល្ប៍ ។

**ប្រការ២:**

ត្រូវបានប្រគល់ភារកិច្ច ដូចខាងក្រោម ÷

១- លោក **ពៅ ម៉ូលីណែល** មន្ត្រីផ្នែកច្បាប់អន្តរជាតិនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ ឯកទេសប្រវត្តិវិទ្យា ជាអនុប្រធាននៃគណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រនយោបាយនិងការទូត ជំនួសលោកសាស្ត្រាចារ្យបណ្ឌិត **គា គីរីរេណុល**

២- លោក **ម្លិច តិរម្យ** មន្ត្រីវិទ្យាស្ថានភាសាជាតិឯកទេសភាសាវិទ្យា ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ជំនួសលោក **អ៊ឹក សៅបុល**

៣- លោកសាស្ត្រាចារ្យ **គុយ រិន** មន្ត្រីវិទ្យាស្ថានភាសាជាតិ ឯកទេសភាសាវិទ្យាជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វប្បធម៌និងវិចិត្រសិល្បៈ ជំនួសលោកស្រី **អ៊ុង ម៉ាល័យ** ។

**ប្រការ៣:**

ត្រូវបានបន្ថែមសមាជិក គណៈកម្មការបច្ចេកស័ព្ទនានា ដូចខាងក្រោម ÷

១- លោកសាស្ត្រាចារ្យបណ្ឌិត **ឆេង វណ្ណារិទ្ធ** ប្រធានផ្នែកនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឯកទេសសេដ្ឋកិច្ច ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ។

២- លោកស្រី **ជា វណ្ណី** មន្ត្រីផ្នែកនរវិទ្យានិងជាតិពន្ធុវិទ្យា ឯកទេស អក្សរសិល្ប៍ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

៣- ឯកឧត្តមសាស្ត្រាចារ្យ **ត្រឹង ងា** ទីប្រឹក្សាអមរាជបណ្ឌិតសភាកម្ពុជា ឯកទេសគ្រប់គ្រង ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រនយោបាយនិងការទូត

៤- លោកសាស្ត្រាចារ្យ **លាង សុភាព** អនុប្រធានផ្នែកខេមរនីយកម្ម វចនានុក្រម និងបកប្រែ ឯកទេសគ្រប់គ្រង ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រនយោបាយ និងការទូត

៥- លោកស្រី **ហេង ជារី** មន្ត្រីផ្នែករដ្ឋបាល ឯកទេសវិទ្យាសាស្ត្រនយោបាយ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រនយោបាយ និងការទូត

៦- លោកសាស្ត្រាចារ្យ **ប៊ី សុខគង់** មន្ត្រីវិទ្យាស្ថានភាសាជាតិ ឯកទេសភាសាវិទ្យា ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ភាសាវិទ្យា និងអក្សរសិល្ប៍

៧- លោកស្រីសាស្ត្រាចារ្យ **តាង ណារង** មន្ត្រីវិទ្យាស្ថានភាសាជាតិ ឯកទេសអក្សរសិល្ប៍ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ភាសាវិទ្យា និងអក្សរសិល្ប៍

៨- លោកសាស្ត្រាចារ្យ **ឈុន សុខា** មន្ត្រីវិទ្យាស្ថានភាសាជាតិ ឯកទេសអក្សរសិល្ប៍ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ភាសាវិទ្យា និងអក្សរសិល្ប៍

៩- លោកសាស្ត្រាចារ្យបណ្ឌិត **នៅ ស៊ុន** មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ឯកទេសភាសាវិទ្យា ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ភាសាវិទ្យា និងអក្សរសិល្ប៍

១០- លោកស្រីសាស្ត្រាចារ្យបណ្ឌិត **ឈុំ ណារី** ប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឯកទេសរូបវិទ្យា ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

១១- លោកសាស្ត្រាចារ្យ **តាត់ ចាន់ថា** លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ឯកទេសបច្ចេកវិទ្យា ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

១២- លោកសាស្ត្រាចារ្យបណ្ឌិត **ហ៊ឹម សុភី** ប្រធានផ្នែកសិល្បៈប្រជាប្រិយនៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ ឯកទេសវិទ្យាសាស្ត្រសិល្បៈ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទវប្បធម៌ និងវិចិត្រសិល្បៈ

១៣- លោកសាស្ត្រាចារ្យ **ឈឹម សុខាន់ដារ៉ា** មន្ត្រីវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ ឯកទេសបុរាណវិទ្យា ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វប្បធម៌ និងវិចិត្រសិល្បៈ

១៤- លោកសាស្ត្រាចារ្យបណ្ឌិត **គឹម ពីនន់** ព្រឹទ្ធបុរសមហាវិទ្យាល័យសិល្បៈនាដសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ឯកទេសវិទ្យាសាស្ត្រសិល្បៈ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ វប្បធម៌ និងវិចិត្រសិល្បៈ

១៥- លោក **ចាន់ ប៊ុន្នី** លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម ឯកទេសគ្រប់គ្រងសាធារណៈ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម

១៦- លោក **តាំង ស៊ិន** មន្ត្រីនៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម ឯកទេសបសុពេទ្យ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម

១៧- លោក **សួន សុភា** មន្ត្រីនៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម ឯកទេសក្សេត្រសាស្ត្រ ជាសមាជិកនៃគណៈកម្មការបច្ចេកស័ព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម

១៨- លោក **អាត ចាវ៉ា** មន្ត្រីនៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម ឯកទេសវេជ្ជសាស្ត្រ ជាសមាជិកនៃគណៈកម្មការបច្ចេកសព្ទ ជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម ។

**ប្រការ៤:** ប្រធានការិយាល័យរដ្ឋបាល ប្រធានការិយាល័យហិរញ្ញវត្ថុ ប្រធានការិយាល័យបោះពុម្ពផ្សាយ ប្រធានគណៈកម្មការបច្ចេកសព្ទពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ប្រការ២ និងប្រការ៣ខាងលើ ត្រូវអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី 14 ខែ 12 ឆ្នាំ២០០៩*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធាន គណៈកម្មាធិការជាតិភាសាខ្មែរ**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រាជបណ្ឌិតសភាកម្ពុជា
- សមាជិក គណៈកម្មាធិការជាតិភាសាខ្មែរ
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ